ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៥៧៤ ក្រ.ផ "ស"
-ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ៧៣៧០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ៥៤៧១ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ២១៤១ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ

កាលបរិច្ឆេទបើកសវនាការ ៖ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង៨ ព្រឹក

កាលបរិច្ឆេទប្រកាសសាលក្រម៖ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង៨និង០០នាទីព្រឹក

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ជាចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

លោកស្រី [redacted] ជាចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៧៣៧០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ រវាងមាន**ជនជាប់ចោទ**៖

១-ឈ្មោះ [redacted] **វណ្ណឫទ្ធ** ហៅ **លីន** ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបុគ្គលិកអនាម័យ កំរិតវប្បធម៌ថ្នាក់ទី០៣ថ្មី ឪពុកឈ្មោះ [redacted] **សារ៉ាន់** "ស្លាប់" ម្តាយឈ្មោះ [redacted] **សុជាតិ** "រស់" ប្រពន្ធឈ្មោះ [redacted] **ជឿន** "រស់" មានកូន០៣នាក់ ជានីតិជន ទោសពីមុនធ្លាប់ជាប់មណ្ឌលអប់រំកែប្រែឱកាសខ្ចី រយៈពេល០៥ខែ ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន (ក្នុងឃុំ) ។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ១១០៥៥ "ព" ដយដ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ (ម១) ។

មានលោក [redacted] ជាមេធាវីការពារក្តី ។

២-ឈ្មោះ [redacted] **ជឿន** ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរវិស្វករគីមីឧស្សាហកម្ម ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នផ្ទះជួល ផ្លូវលេខ៣៦៩ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **មើង** "ស្លាប់" ម្តាយឈ្មោះ **ហួន** "ស្លាប់" ប្តីឈ្មោះ [redacted] **វណ្ណឫទ្ធ** ហៅ **លីន** "រស់" មានកូន០៣នាក់ ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារព្រៃសចំនួន០១លើក រយៈពេល ០៦ខែ (ក្រៅឃុំ) ។

Scanned with CamScanner

-ដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៥៣៥ "ព" ដ.ព.ស ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ ។

មានលោកស្រី [redacted] ជាមេធាវីការពារក្តី ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចមុខតូបលេខ២១២ ផ្លូវលេខ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សួដា** ភេទស្រី អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ២៩ ផ្លូវបេតុង ភូមិទួលរកាទី១ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

អត្ថហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង០០ និង៤០នាទី ជនត្រូវចោទឈ្មោះ [redacted] **វណ្ណាឫរ៉ាត់** ហៅ **លីន** និងជនជាប់ចោទឈ្មោះ [redacted] **ធឿន** បាននាំគ្នាដើរចេញពីផ្ទះមានទីតាំងស្ថិតនៅចំណុចផ្ទះជួល ផ្លូវលេខ៣៦៩ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក្នុងគោលបំណងលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ។ លុះដើរដល់ចំណុចមុខតូបលេខ២១២ ផ្លូវលេខ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលជាតូបរបស់ឈ្មោះ [redacted] **សួដា** ភេទស្រី អាយុ៥៣ឆ្នាំ ដោយឃើញមានសភាពស្ងាត់ជនជាប់ចោទឈ្មោ [redacted] **វណ្ណាឫរ៉ាត់** ហៅ **លីន** បានយកដែកចុងស្រួចផ្តុះមេសោតូបខាងលើ និងឱ្យជនជាប់ចោទឈ្មោះ [redacted] **ធឿន** ជាអ្នកចាំមើលផ្លូវរួចនាំគ្នាចូលទៅលួចបន្តែមួយចំនួនរួមមាន៖១.ស្តែតឿ, ២.ស្តែក្រញ៉ាញ់, ៣.ស្តែខ្មៅ, ៤.ស្តែចង្កឹះ, និង៥.ដើមខាត់ណា សរុបទម្ងន់ប្រហែល ចំនួន៥០គីឡូក្រាម រួចក៏បានយកទៅលក់ឱ្យស្ត្រីម្នាក់មិនស្គាល់ឈ្មោះ អាយុ៥៤ឆ្នាំ ស្ថិតនៅម្តុំដើមស្វែង។ ក្រោយមកឈ្មោះ [redacted] **សួដា** បានត្រឡប់មកកាន់តូបរបស់ខ្លួនក៏ឃើញមេសោតូបរបើក ស្រាប់តែចាត់បន្តែអស់ទើបឈ្មោ [redacted] **សួដា** និងឈ្មោះ [redacted] **ប៊ុនឡេង** ភេទប្រុស អាយុ៥៥ឆ្នាំ ដឹងថាមានចោរចូលលួចបន្តែ បន្ទាប់មកជនរងគ្រោះក៏ស្វែងរកជនជាប់ចោទរហូតដល់ម៉ោង១១ និង០០នាទី នៅថ្ងៃដដែល នៅចំណុចមុខផ្ទះគ្មានលេខ ផ្លូវ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជនរងគ្រោះក៏ប្រទះឃើញជនជាប់ចោទទាំង០២នាក់ ត្រូវបានសន្តិសុខផ្សារឃាត់ខ្លួន ហើយជនជាប់ចោទទាំង០២នាក់នោះបានសារភាពថា ពិតជាបានលួចបន្តែរបស់ជនរងគ្រោះប្រាកដមែន ភ្លាមនោះជនរងគ្រោះក៏បាននាំជនត្រូវចោទទាំង០២នាក់ យកទៅប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលច្បារអំពៅ២ និងដាក់ពាក្យបណ្តឹងប្តឹងលើជនជាប់ចោទទាំង០២នាក់ខាងលើ បន្ទាប់មកសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនតាមនីតិវិធីតែម្តង ។

-**បានឃើញ** របាយការណ៍សំយោគលេខ១៦៧/២៣ រ.ប.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌជ្រោយចង្វារ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៥៥៥៧ អ.យ.ព ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

Scanned with CamScanner

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ១១១៨ អ.ឃ.ព ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់លោក **សេង ម៉ែងស្រ៊ីន** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចបញ្ឈប់សំណុំរឿងទៅជំនុំជម្រះលេខ២០៥៨ "ព" ដ.ដ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ របស់លោក [redacted] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោ[redacted]**វណ្ណឫទ្ធ** ហៅ **លីន** បានឆ្លើយថា៖ខ្លួននិងប្រពន្ធរបស់ខ្លួនឈ្មោះ[redacted] **ធឿន** ពិតជាបានលួចបន្ទែរបស់គេពិតមែន ពេលលួចបានហើយយកទៅលក់បានប្រាក់ចំនួន៨០.០០០ រៀល ហើយលុយនោះប្រពន្ធរបស់ខ្លួនបានយកទៅទិញអីហូប ព្រោះគាត់មានផ្ទៃពោះជិតគ្រប់ខែ ។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយឈ្មោះ[redacted] **ធឿន** បានឆ្លើយថា៖កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ ខ្លួន និងឈ្មោ[redacted] **វណ្ណឫទ្ធ** បានដើរចេញពីផ្ទះនៅម្តុំភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដើម្បីដើរទៅរើសអេតចាយ ចំណែកឯជនជាប់ចោទឈ្មោះ[redacted] **វណ្ណឫទ្ធ** បានដើរទៅបោសសម្រាម លុះដើរទៅដល់ចំណុចមុខតូបគ្មានលេខដោយមានសភាពស្ងាត់ ភ្លាមនោះខ្លួនបានធ្វើសកម្មភាពយកដែកចុងស្រួចផ្តិះសោតូបលួចយកបន្ទែ បានចំនួន០២ស្បោង បានសម្រេច ។ បន្ទាប់ពីលួចបានសម្រេច ខ្លួនបានអូសចង់បន្ទែចេញពីតូបនោះ ដោយស្បោងបន្ទែមានតាមផ្លូវជាតិលេខ១ ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ បានប្រាក់ចំនួន៨០,០០០៛ (ប្រាំបីម៉ឺនរៀល) យកទៅស៊ីចាយ និងដោយសារខ្លួនមានផ្ទៃពោះជិតគ្រប់ខែ ដើម្បីជាសុខភាពកូនក្នុងពោះ ។ លុះដល់វេលាម៉ោង១១ និង០០នាទី ខ្លួន និងជនជាប់ចោទឈ្មោ[redacted] **វណ្ណឫទ្ធ** កំពុងតែដើរនៅលើផ្លូវ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏ត្រូវបានសមត្ថកិច្ចឃាត់រូបខ្លួន និងឈ្មោះ[redacted] **វណ្ណឫទ្ធ** តែម្តង ។

-ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **សុងា** នៅចៅក្រមស៊ើបសួរថា៖ ខ្លួនសូមរក្សាពាក្យបណ្តឹងចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ និងកំណត់ហេតុបណ្តឹង ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ នៅចំពោះមុខមន្ត្រីនគរបាលទុកជាបានការដដែល ។ ខ្លួនជាអ្នកលក់បន្ទែនៅផ្សារច្បារអំពៅ ដោយនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង០៤ទៀបភ្លឺ ខ្លួនបានឱ្យកម្មករទៅបើកស្តង់អូសបន្ទែមកលក់ ពេលនោះកម្មករខ្លួនបានប្រាប់ថាមានចោរគាត់សោរស្តង់បាត់បន្ទែចំនួន០២ករណីហើយ ខ្លួនបានមកមើលពិតជាមានបាត់បន្ទែមែន ចោរគាស់សោរស្តង់មែន ខ្លួនបានប្តឹងមកសន្តិសុខផ្សារ ពេលនោះក៏សន្តិសុខបានឃាត់ខ្លួនមនុស្សពីរនាក់ ស្រីម្នាក់ និងប្រុសម្នាក់ មកសួរនាំបានឆ្លើយសារភាពថាពិតជាបានលួចបន្ទែរបស់ខ្លួនប្រាកដមែន ។ ខ្លួនប្តឹងទាមទារប្រាក់ចំនួន៣០០.០០០(សាមសិបម៉ឺន)រៀល ជាថ្លៃបន្ទែ ដោយបន្ទែរបស់ខ្លួនបានបាត់បង់អស់ចំនួន៨០គីឡូក្រាម មានស្ពៃចង្កឹះ ស្ពៃក្រញាញ់ ស្ពៃខ្មៅ និងខាត់ណា មិនទាមទារសំណងជម្ងឺចិត្ត និងខាតបង់ពេលវេលានោះទេ និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ[redacted] **ប៊ុនឡេង** បានឆ្លើយនៅចៅក្រមស៊ើបសួរថា៖ខ្លួនធ្វើជានគរបាលយាមនៅផ្សារច្បារអំពៅ ផ្សារបន្ទែ ពេលនោះមានឈ្មោ[redacted] **សុងា** ភេទស្រី ជាអ្នកលក់បន្ទែ បានមកប្រាប់ខ្លួនថាមានចោរ

លួចគាស់តូបបន្លែ បាត់បន្លែអស់ចំនួន៥០គីឡូក្រាម ខ្លួនក៏បានស្រាវជ្រាវសួរអ្នកទិញបន្លែពីចោរ ក៏ឈានដល់ការឃាត់ខ្លួនមនុស្សស្រីពីរនាក់ ស្រីម្នាក់ ប្រុសម្នាក់ ប្រគល់ឱ្យនគរបាលប៉ុស្តិ៍ច្បារអំពៅ២តែម្តង ។

សេចក្តីសន្និដ្ឋានឆ្លើយសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយការដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទពិតជាបានធ្វើសកម្មភាពឆក់យកកាបូបរបស់ជនរងគ្រោះពិតប្រាកដមែន ដូច្នេះស្នើសុំតម្កល់ពីការសន្និដ្ឋានស្តាពរទុកជាបានការដដែល និងសុំឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] **វណ្ណឫទ្ធ** ហៅ **លីន** បានធ្វើសេចក្តីសន្និដ្ឋានថា៖ក្មួនក្តីរបស់ខ្លួនបានឆ្លើយសារភាព ដឹងពីកំហុសដែលខ្លួនបានប្រព្រឹត្ត ដូច្នេះស្នើសុំឱ្យតុលាការបន្ធូបន្ថយទោសឱ្យក្មួនក្តីខ្លួនផង ។

លោកស្រី [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោ[redacted] **ជឿន** បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការដេញដោលនាពេលសវនាការ និងស្តាប់អំណានចម្លើយរបស់ក្មួនក្តីខ្លួនឃើញថា ក្មួនក្តីខ្លួនបានឆ្លើយសារភាពហើយថា គាត់ពិតជាបានធ្វើសកម្មភាពយកដែកចុងស្រួចផ្តិះសោតូបលួចយកបន្លែបានចំនួន០២ស្បោង ក្រោយពីលួចបានហើយបានឱ្យប្តីឈ្មោ[redacted] **វណ្ណឫទ្ធ** យកទៅលក់បានលុយចំនួន៨ម៉ឺនរៀល បន្ទាប់មកក្មួនក្តីខ្លួនយកលុយនោះទៅទិញអីហូបព្រោះក្មួនក្តីខ្លួនមានផ្ទៃពោះជិតគ្រប់ខែដើម្បីសុខភាពកូនក្នុងផ្ទៃ ។ ក្នុងនាមខ្លួនជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោ[redacted] **ជឿន** ស្នើសុំឱ្យតុលាការមេត្តាបន្ធូបន្ថយទោសឱ្យក្មួនក្តីខ្លួនផង ព្រោះគាត់ប្រព្រឹត្តបទល្មើសដោយសារតែគ្មានចំណេះដឹង ជីវភាពខ្វះខាត គ្មានលុយទិញអីហូប ដើម្បីសុខភាពកូនក្នុងផ្ទៃតែប៉ុណ្ណោះ ។

សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោ[redacted] **វណ្ណឫទ្ធ** ហៅ **លីន** បាននិយាយសម្តីចុងក្រោយបង្អស់ថា៖ សុំឱ្យបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោ[redacted]**ណ្ណឫទ្ធ**

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] **ជឿន**

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

Scanned with CamScanner

សំអាងហេតុ

១-យោងតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ និង ធ្លង តាមការសាកសួរដេញដោលនាពេលសវនាការកំណត់បានថា កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ មានអំពើ **លួចមានស្ថានទម្ងន់ទោស(យកដែកឆ្កឹះមេសោ)** តាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចមុខតូបលេខ ២១២ ផ្លូវលេខ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បង្កឡើងដោយឈ្មោះ[redacted] **វណ្ណឫទ្ធ** ហៅ **លីន** និងឈ្មោះ[redacted] **ធឿន** ពិតប្រាកដមែន ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] **វណ្ណឫទ្ធ** ហៅ **លីន** បានឆ្លើយសារភាពថា៖ខ្លួននិងប្រពន្ធរបស់ខ្លួន ឈ្មោះ[redacted] **ធឿន** ពិតជាបានលួច បន្ទែរបស់គេពិតមែន ពេលលួចបានហើយយកទៅលក់បានប្រាក់ចំនួន៨0.000 រៀល ហើយលុយនោះប្រពន្ធរបស់ខ្លួនបានយកទៅទិញអីហួប ព្រោះគាត់មានផ្ទៃពោះជិតគ្រប់ខែ ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] **ធឿន** បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ ខ្លួន និងឈ្មោ[redacted] **វណ្ណឫទ្ធ** បានដើរចេញពីផ្ទះនៅម្តុំភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដើម្បីដើរទៅរើសអេតចាយ ចំណែកឯជនជាប់ចោទឈ្មោះ[redacted] **វណ្ណឫទ្ធ** បានដើរទៅបោសសម្រាម លុះដើរទៅដល់ ចំណុចមុខតូបគ្មានលេខដោយមានសភាពស្ងាត់ ភ្លាមនោះខ្លួនបានធ្វើសកម្មភាពយកដែកចុងស្រួចឆ្កឹះសោតូបលួចយកបន្ទែ បានចំនួន០២ស្បោង បានសម្រេច ។ បន្ទាប់ពីលួចបានសម្រេច ខ្លួនបានអូសចង់បន្ទែចេញពីតូបនោះ ដោយស្បោងបន្ទែ មានតាមផ្លូវជាតិលេខ១ ភូមិដើមស្ពែង សង្កាត់ច្បារអំពៅ២ បានប្រាក់ចំនួន៨0,000៛ (ប្រាំបីម៉ឺនរៀល) យកទៅស៊ីចាយ និងដោយសារខ្លួនមានផ្ទៃពោះជិតគ្រប់ខែ ដើម្បីជាសុខភាពកូនក្នុងពោះ ។ លុះដល់វេលាម៉ោង១១ និង០០នាទី ខ្លួន និងជន ជាប់ចោទឈ្មោះ[redacted] **វណ្ណឫទ្ធ** កំពុងតែដើរនៅលើផ្លូវ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានី ភ្នំពេញ ក៏ត្រូវបានសមត្ថកិច្ចឃាត់រូបខ្លួន និងឈ្មោះ[redacted] **វណ្ណឫទ្ធ** តែម្តង ។

៤-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោ[redacted] **វណ្ណឫទ្ធ** ហៅ **លីន** និងឈ្មោ[redacted] **ធឿន** បានធ្វើសកម្មភាពយក ដែកឆ្កឹះមេសោ ពីតូបរបស់ជនរងគ្រោះ ដែលធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់សង្គមយ៉ាងធ្ងន់ធ្ងរ គឺមានធាតុផ្សំជាបទល្មើស **លួចមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចមុខតូបលេខ ២១២ ផ្លូវលេខ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣។

៥-ជនជាប់ចោទឈ្មោះ[redacted] **វណ្ណឫទ្ធ** ហៅ **លីន** និងឈ្មោះ[redacted] **ធឿន** ជានីតិជនដែលមានសមត្ថភាព និងស្មារតី គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើផ្ទាល់ខ្លួននៅពេលប្រព្រឹត្តបទល្មើស ។

៦-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និង មូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពរបស់ជន ជាប់ចោទឈ្មោ[redacted] **វណ្ណឫទ្ធ** ហៅ **លីន** ភេទប្រុស អាយុ៣៥ឆ្នាំ និងឈ្មោះ[redacted] **ធឿន** ភេទស្រី អាយុ៣៤ឆ្នាំ ពីបទ **លួច មានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចមុខតូបលេខ២១២ ផ្លូវលេខ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣។

៧-នៅក្នុងរឿងនេះជនរងគ្រោះឈ្មោះ[redacted] **សួងា** ប្តឹងសុំទាមទារសំណងរដ្ឋប្បវេណីពីជនជាប់ចោទចំនួន ៣00.000 (បីសែនរៀល) ជាថ្លៃបន្ទែ នោះតុលាការមិនលើកយកមកពិចារណាទេ ព្រោះបន្ទែដែលជនជាប់ចោទលួច នោះមានតម្លៃត្រឹមតែ៨0.000រៀល ម្យ៉ាងទៀតជនជាប់ចោទលួចដើម្បីយកលុយទិញអីហួបដើម្បីកូនក្នុងផ្ទៃតែប៉ុណ្ណោះ ។

Scanned with CamScanner

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] **វណ្ណឬទ្ធ** ហៅ **លីន** ភេទប្រុស អាយុ៣៥ឆ្នាំ និងជនជាប់ចោទឈ្មោះ[redacted] **ធឿន** ភេទស្រី អាយុ៣៤ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស(យកដែកគ្រឹះមេសោ)** តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចមុខតូបលេខ២១២ ផ្លូវលេខ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣។

<u>ហេតុដូច្នេះសម្រេច</u>

-ផ្តន្ទាទោសលើឈ្មោះ[redacted] **វណ្ណឬទ្ធ** ហៅ **លីន** ភេទប្រុស អាយុ៣៥ឆ្នាំជនជាតិខ្មែរ និងឈ្មោះ[redacted] **ធឿន** ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់កំណត់ **០៣ (បី) ឆ្នាំ** ។

ពីបទ **លួចមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** និងមាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចមុខតូបលេខ២១២ ផ្លូវលេខ៣៦៧ ភូមិកណ្តាល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] **វណ្ណឬទ្ធ** កំបាំងមុខជនជាប់ចោទឈ្មោះ[redacted] **ធឿន** និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤ ។

គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា និងត្រា[redacted]

.....

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

ថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

ក្រឡាបញ្ជី

[redacted]

[redacted]

Scanned with CamScanner